សំណួរដែល
គេតែងតែសួរ
ជាញឹកញាប់

# ប្រព័ន្ធស្ទង់មើលសាលានៅរដ្ឋផិនសល់វេញ៉ា (PSSA)
## ការស្ទង់មើលផ្នែកគណិតសាស្រ្តនិងអាន
## ថ្នាក់ទី៣-ទី៨ និង ទី១១ – មិនា ២០០៩
## ពត៌មានសម្រាប់មាតាបិតាឬអាណាព្យាបាល

**តើសាលាណាខ្លះដែលចូលរួម?**

សាលារបស់ក្រសួងអប់រំទាំងអស់ចូលរួមក្នុងការស្ទង់មើលគណិតសាស្រ្តនិងអាន ។ សាលាដែលមិនមែនជាសាលាសាធារណៈនិង សាលា ឯកជនក៏អាចចូលរួមតាមការស្ម័គ្រចិត្ត។

**តើសិស្សណាខ្លះដែលត្រូវមានការស្ទង់មើល?**

សិស្សទាំងអស់ដែលរៀនថ្នាក់ទី៣ - ទី៨ និងទី១១ ត្រូវតំរូវឲ្យ មានការស្ទង់មើល (លើកលែងតែសិស្សមួយចំនួនតូចដែលត្រូវ តាមលក្ខណៈវិនិច្ឆ័យចំៗណាមួយ)។

**តើការស្ទង់មើលធ្វើឡើងនៅពេលណា?**

ការស្ទង់មើលណាត់ពេលដោយក្រសួងអប់រំ រយៈពេលធ្វើតេះ ចាប់ពីខែមិនា ទី១៦ ដល់ ខែមិនា ទី២៧ ឆ្នាំ២០០៩ ។

**តើការស្ទង់មើលនេះស៊ីពេលប៉ុន្មាន?**

ការស្ទង់មើលគណិតសាស្រនិងអាន្ត ស៊ីពេលប្រហែលពីរទៅ ប្រាំមួយទៅប្រាំពីរម៉ោង ទើបធ្វើចប់។ ក្រសួងអប់រំរបស់លោក អ្នកនឹងជូនដំណឹងដល់លោកអ្នកអំពីពេលវេលាស្ទង់មើល។

**តើការស្ទង់មើលមានអ្វីខ្លះ?**

សិស្សម្នាក់ៗបំពេញប្រការនៃការស្ទង់មើលបីជំពូក សម្រាប់ គណិតសាស្រ្តនិងអាន។ ជំពូកខ្លះដូចៗគ្នា សម្រាប់សិស្សទាំង អស់ ហើយជំពូកខ្លះទៀតនឹងមានក្រុមប្រការខុសៗគ្នា។

**តើការស្ទង់មើលមានសំណួរប្រភេទណាខ្លះ?**

សិស្សឆ្លើយសំណួរពីរប្រភេទៈ រើសយកចំឡើយមួយពីសំណួរ ជាច្រើន និងឆ្លើយតាមការសរសេរ។ ការរើសយកចំឡើយមួយ ពីសំណួរជាច្រើន គឺរើសយកចំឡើយមួយដែលត្រូវ ចេញពីសំ ណួរបួនដែលដាក់ឲ្យ ហើយចំឡើយតាមការសរសេរ តំរូវឲ្យ សិស្សសរសេរនូវចំឡើយរបស់ពួកគេ។

**តើសិស្សទទួលពិន្ទុរបៀបណា សរាប់ចំឡើយតាមការសរសេរ?**

ចំឡើយតាមការសរសេរសម្រាប់គណិតសាស្រ្តនិងអាននឹងឲ្យពិន្ទុដោយអ្នក ឲ្យពិន្ទុដែលមានការហ្វឹកហ្វឺនតាមប្រព័ន្ធឲ្យពិន្ទុដែល មានការសំរេចជាមុន។ ក្នុងការអាននិងគណិតសាស្រ្ត ការឲ្យពិន្ទុ យោងទៅតាមអ្វីៗដែលមានតែប៉ុណ្ណោះ។ ការប្រកបនិងវិធីប្រើ វណ្ណយុត្ត គឺមិនរាប់បញ្ចូលក្នុងការឲ្យពិន្ទុទេ។

**តើអ្នកណាជាអ្នកសំរេចថាត្រូវធ្វើអ្វីខ្លះក្នុងការស្ទង់មើល?**

ក្រុមអ្នកវិជ្ជាកោសល្យគ្រប់ជាន់ថ្នាក់ទាំងអស់នៅរដ្ឋផិនសល់វេញ៉ា ជ្រើសរើសមុខវិជ្ជាដែលយកមកស្ទង់មើល។ ក្រុមនេះមានទាំង គ្រូបង្រៀន អ្នកមើលខុសត្រូវ នាយកនៃកម្មវិធី និងអ្នកឯកទេស នៅមហាវិទ្យាល័យ។ ហើយក្រុមនេះ ពិនត្យមើល ពិនិត្យផ្ទៀង ផ្ទាត់ ហើយយល់ព្រមនូវប្រការដែលបានសរសេរដើម្បីឲ្យស្រប តាមមូលដ្ឋានស្ទង់មើលរបស់រដ្ឋផិនសល់វេញ៉ា។

**តើអ្នកណាជាអ្នកធ្វើការស្ទង់មើល?**

សាលានិមួយៗរើសអ្នកដែលធ្វើការស្ទង់មើល។ ភាគច្រើន អ្នក ទាំងនេះគឺជានិស្សិតដែលហាត់រៀនឲ្យក្លាយទៅជាគ្រូបង្រៀន ដែលតែងតែមានជំនួយពីចាងហ្វាងសាលាឬអ្នកឲ្យឱវាទនៅសា លា។

**តើការស្ទង់មើលលើការអានមានអ្វីខ្លះ?**

ការស្ទង់មើលលើការអាន សំដៅទៅលើការរាយការណ៍ធំពីរ។ សិស្សអានរឿងប្រឌិតនិងមិនប្រឌិត ហើយឆ្លើយសំណួរអំពីរឿង ទាំងនេះ។ ដោយឆ្លើយនឹងរឿងទាំងនេះ សិស្សបង្ហាញនូងការ យល់ដឹងនិងការប៉ិនប្រសប់ក្នុងការអាន ហើយធ្វើពិភាគនិងធ្វើការ បកប្រែរឿងប្រឌិតនិងមិនប្រឌិត។

**តើការស្ទង់មើលលើគណិតសាស្រ្តមានអ្វីខ្លះ?**

ការស្ទង់មើលលើគណិតសាស្រ្ត សំដៅទៅលើការរាយការណ៏ធំ ប្រាំ។ ជំពូកនិមួយៗគឺខុសៗគ្នា ទៅតាមក៏រិតថ្នាក់។ ផ្នែករាយ ការណ៍ប្រភេទ A *មានលេខនិងធ្វើលេខ* សិស្សឆ្លើយសំណួរ តាមជំពូកពិសេសៗ ដែលមិនអនុញ្ញាតឲ្យប្រើម៉ាស៊ីនគិតលេខ សំណួរក្នុងការស្ទង់មើលតម្រូវឲ្យសិស្សបង្ហាញនូវការគិតលេខ ទាំងអស់របស់ពួកគេ (របៀបគិតលេខ គូរក្រាហ្វិក គូររូប ។ល។ ហើយពន្យល់តាមការសរសេរថាតើពួកគេដោះស្រាយចំណោទ ដោយរបៀបណា។

**តើលទ្ធផលត្រូវរាយការណ៏របៀបណា?**

សេចក្ដីរាយការណ៍សម្រាប់ការអាននិងគណិតសាស្រ្តត្រូវបញ្ជូន ទៅក្រសួងអប់រំដើម្បីចែកចាយទៅមាតាបិតា គ្រូ និងអ្នកឲ្យឱវាទ នៅសាលា និង/ឬចាងហ្វាងសាលា។ រដ្ឋនឹងមិនទទួលនូវសេចក្ដី រាយការណ៍ណា ដែលមានឈ្មោះសិស្សទេ។

លទ្ធផលត្រូវបានរាយការណ៏ដោយសាលា សម្រាប់គោលបំណង នៃកម្មវិធីនិងគំរោងការណ៏។ ក្រសួងអប់រំបោះពុម្ពលទ្ធផលនៃការ ធ្វើតេះ PSSA សម្រាប់សាលានិមួយៗ។ រដ្ឋក៏បញ្ចេញទិន្នន័យនៃ ការស្ទង់មើលរបស់សាលានិមួយៗដែរ។

**តើមាតាបិតាអាចមើលការស្ទង់មើលបានទេ?**

មាតាបិតាឬអាណាព្យាបាលអាចពិនិត្យមើលការស្ទង់មើលទាំងនេះ ដោយធ្វើការរៀបចំជាមួយអ្នកចាត់ចែងខាងការស្ទង់មើលនៅសាលា ពេលណាការស្ទង់មើលមកដល់សាលា។ ការស្ទង់មើលឬកំ ណត់សំគាល់អំពីប្រការនាៗមិនអាចយកចេញទៅក្រៅសាលាបានទេ ហើយត្រូវមានការចុះហត្ថលេខាពីការរក្សាទុកជាសម្ងាត់។ ក្រោយពីបានពិនិត្យមើលការស្ទង់មើលរួចហើយ បើមាតាបិតាមិន ចង់ឲ្យកូនចូលរួមក្នុងការស្ទង់មើលលើការអាននិងគណិតសាស្រ្ត ដោយមានការប៉ះពាល់ដល់ជំនឿសាសនារបស់ពួកគេ ពួកគេអាច សរសេរសំបុត្រទៅអ្នកចាត់ចែងក្រសួងអប់រំ មុនពេលចាប់ផ្ដើម ការស្ទង់មើល ដើម្បីទទួលការអត់អោនអោយកូនពីការធ្វើការ ស្ទង់មើល។